

សង្ខេបរួម

# វឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោក

២០១១-២០១២

# នៅក្នុងការស្វែងរកយុត្តិធម៌

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

# វឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោកឆ្នាំ២០១១-២០១២៖ នៅក្នុងការស្វែងរកយុត្តិធម៌

ការបោះពុម្ពផ្សាយលើកនេះស្តី អំពីវឌ្ឍនភាពរបស់ស្ត្រីក្នុងពិភពលោកចាប់ផ្តើមឡើងជាមួយនឹងគោលការណ៍៖ សតវត្សកន្លងមកគឺជាការផ្លាស់ប្តូរទាំងស្រុងនៅក្នុងសិទ្ធិរបស់ស្ត្រីដោយប្រទេសទាំងឡាយក្នុងតំបន់បានពង្រីកវិសាលភាពនៃបុព្វសិទ្ធិស្របច្បាប់របស់ស្ត្រី។ ទោះបីជាយ៉ាងណាក្តី សម្រាប់ស្ត្រីភាគច្រើននៅក្នុងពិភពលោកច្បាប់ដែលមាននៅលើក្រដាសមិនបានប្រែក្លាយទៅជាសមភាព និងយុត្តិធម៌នោះទេ។

នៅក្នុងឆ្នាំ១៩១១ មានប្រទេសតែពីរប៉ុណ្ណោះនៅក្នុងពិភពលោកដែលបានអនុញ្ញាតឲ្យស្ត្រីបោះឆ្នោត។ មួយសតវត្សក្រោយមកទៀត សិទ្ធិនេះមានស្ទើរតែទូទាំងសកលលោក ហើយស្ត្រីកំពុងតែប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនកាន់តែច្រើនឡើងនៅក្នុងការធ្វើការសម្រេចចិត្តជាងធ្លាប់មានកន្លងមក។ រួមជាមួយនឹងឥទ្ធិពលផ្នែកនយោបាយកាន់តែធំរបស់ស្ត្រី មានការទទួលស្គាល់កាន់តែច្រើននូវសិទ្ធិរបស់ស្ត្រី មិនត្រឹមតែសិទ្ធិនយោបាយ និងពលរដ្ឋប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ផងដែរ។ បច្ចុប្បន្ននេះប្រទេសចំនួន១៨៦ទូទាំងសកលលោកបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់រើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ដែលជាសញ្ញាបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការឆ្លើយតបទៅនឹងសិទ្ធិមនុស្សរបស់ស្ត្រីនិងក្មេងស្រីដោយបំបែករបាំងឆ្ពោះទៅរកសមភាពយេនឌ័រ និងយុត្តិធម៌។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងខណៈពេលដែលប្រទេសមួយចំនួនបានធ្វើឲ្យមានភាពជឿនលឿនយ៉ាងច្រើននៅក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក៏ស្ត្រីជាញឹកញាប់ត្រូវបានគេបដិសេធមិនឲ្យគ្រប់គ្រងលើរាងកាយរបស់ខ្លួនបដិសេធមិនឲ្យមានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងបដិសេធពីការទទួលបានការការពារពីអំពើហឹង្សា។ ស្ត្រីប្រមាណ៦០០លាននាក់ ពោលគឺច្រើនជាងពាក់កណ្តាលនៃស្ត្រីធ្វើការទូទាំងពិភពលោកធ្វើការងារដែលងាយរងគ្រោះការងារ ដែលគ្មានភាពស្ថិតថេរ ហើយជាញឹកញាប់ស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ការងារ។ បើទោះបីជាមានវឌ្ឍនភាព យ៉ាងច្រើននៅក្នុងក្របខ័ណ្ឌ ច្បាប់ក៏ដោយស្ត្រីរាប់លាននាក់បានរាយការណ៍ឲ្យដឹងថាពួកគេធ្លាប់បានទទួលរងនូវអំពើហឹង្សានៅក្នុងជីវិតរបស់ ពួកគេជាធម្មតាដោយសារដៃគូជិតស្និទ្ធរបស់ពួកគេ។ ទន្ទឹមគ្នានេះដែរការផ្តោតគោលដៅជាលក្ខណៈប្រព័ន្ធនៃអំពើហឹង្សាផ្លូវភេទដ៏សាហាវមកលើស្ត្រី គឺជាបែបផែនមួយនៃជម្លោះសម័យទំនើប ។ ការរើសអើងកាន់តែរីករាលដាលប្រឆាំងនឹងស្ត្រីបង្កើតជារបាំងដ៏ធំមួយដើម្បីសម្រេចបានសិទ្ធិ និងរារាំងដល់វឌ្ឍនភាពទៅលើគោលដៅអភិវឌ្ឍន៍សហស្សវត្សជាគោលវង្វាស់ដែលសហគមន៍អន្តរជាតិបានកំណត់ដើម្បីលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរចាប់តាំងពីការកែលំអរសុខភាពម្តាយរហូតដល់ការអប់រំសកល និងការបញ្ឈប់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍។ ទោះបីជាសមភាពរវាងស្ត្រីនិងបុរសត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនិងទឹកដីចំនួន១៣៩ ក៏ដោយច្បាប់មិនគ្រប់គ្រាន់និងកង្វះខាតការអនុវត្ត បានធ្វើឲ្យការធានាទាំងនេះទៅជាការសន្យាខ្យល់ ដែលមានផលប៉ះពាល់តិចតួចមកលើជីវិតប្រចាំថ្ងៃរបស់ស្ត្រី។ នៅក្នុងបរិបទជាច្រើនទាំងនៅក្នុងប្រទេសអ្នកមាន និងប្រទេសក្រីក្រ ហេដ្ឋារចនាសម្ព័ន យុត្តិធម៌ដែលរួមមាននគរបាល តុលាការ និងប្រព័ន្ធយុត្តិធម៌ កំពុងតែធ្វើឲ្យស្ត្រីបរាជ័យដែលនេះបង្ហាញយ៉ាងច្បាស់នៅក្នុងសេវាកម្មមិនល្អនិងអាកប្បកិរិយាប្រទូសរ៉ាយពីសំណាក់មនុស្សដែលមានករណីយកិច្ចឆ្លើយតបនឹងសិទ្ធិរបស់ស្ត្រី។

វឌ្ឍនភាពនៃស្ត្រីក្នុងពិភពលោក បង្ហាញថាប្រព័ន្ធច្បាប់និងយុត្តិធម៌ដែលមានដំណើរការល្អ អាចជាយន្តការដ៏សំខាន់បំផុតមួយសម្រាប់ស្ត្រីដើម្បីសម្រេចបានសិទ្ធិរបស់ខ្លួន។ពួកគេអាចតម្រែតម្រង់សង្គមដោយផ្តល់នូវគណនេយ្យភាពបញ្ឈប់ការរំលោភអំណាច និងបង្កើតជាបទដ្ឋានថ្មី។ រហូតមកទល់ពេលនេះតុលាការ គឺជាទីកន្លែងដែលមានសារៈសំខាន់បំផុតនៃគណនេយ្យភាពសម្រាប់ស្ត្រីម្នាក់ៗ ដើម្បីទាមទារសិទ្ធិនិងដើម្បីកំណត់ពីករណីយុត្តិសាស្ត្រច្បាប់ដែលបានផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីរាប់លាននាក់ទៀត។ របាយការណ៍នេះរំលេចពីវិធីដែលរដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការរួមគ្នាដើម្បីកែទម្រង់ច្បាប់និងបង្កើតគំរូថ្មីសម្រាប់ការផ្តល់សេវាយុត្តិធម៌ដែលឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី។ របាយការណ៍នេះបង្ហាញផងដែរពីរបៀបជំនះនូវបញ្ហាប្រឈមដើម្បីធានាថា ស្ត្រីអាចទទួលបានយុត្តិធម៌នៅក្នុងស្ថានភាពលំបាកបំផុត ដែលរួមទាំងបរិបទនៃពហុភាពផ្នែកច្បាប់ និងក្នុងកំឡុងពេលនិងក្រោយពេលមានជម្លោះ។

វឌ្ឍនភាពនៃស្ត្រីក្នុងពិភពលោកកំណត់នូវអនុសាសន៍ ចំនួនដប់ដើម្បីធ្វើឲ្យប្រព័ន្ធយុត្តិធម៌មានដំណើរការសម្រាប់ស្ត្រី។ អនុសាសន៍ទាំងនេះត្រូវបានគេសាកល្បង និងអាចសម្រេចបាន ហើយប្រសិនបើត្រូវបានអនុវត្តវាមានសក្តានុពលយ៉ាងច្រើនក្នុងការបង្កើនលទ្ធភាពរបស់ស្ត្រីដើម្បីទទួលបានយុត្តិធម៌ និងជំរុញសមភាពយេនឌ័រ។

# គាំទ្រអង្គការស្របច្បាប់របស់ស្ត្រី

អង្គការស្របច្បាប់របស់ស្ត្រីស្ថិតនៅជួរមុខនៃការធ្វើឲ្យប្រព័ន្ធយុត្តិធម៌មានដំណើរការសម្រាប់ស្ត្រី។ នៅទីណាដែលជំនួយផ្នែកច្បាប់ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលមានកម្រិត អង្គការស្ត្រីឈានជើងចូលមកដើម្បីផ្តល់យោបល់និងការគាំទ្រដែលស្ត្រីត្រូវការដើម្បីជំរុញសំណុំរឿងច្បាប់មួយដើម្បីបញ្ឈប់អំពើហឹង្សាដើម្បីស្វែងរកការលែងលះគ្នា ឬដើម្បីទាមទារដីធ្លីដែលជាកម្មសិទ្ធិរបស់ពួកគេដោយត្រឹមត្រូវ។

អង្គការទាំងនេះបានជំរុញដល់កិច្ចខិតខំប្រឹងប្រែងកែទម្រង់ច្បាប់ និងសំណុំរឿងបណ្តឹងវិវាទជាយុទ្ធសាស្ត្រដែលមានផ្លាស់ប្តូរស្ថានភាពសម្រាប់សិទ្ធិស្ត្រីនៅថ្នាក់ប្រទេស ថ្នាក់តំបន់និងថ្នាក់អន្តរជាតិ(មើលប្រអប់ទី1)។ ពួកគេក៏ធ្លាប់ជាអ្នកដឹកនាំផងដែរនៅក្នុងអន្តរាគមន៍ដោយជោគជ័យក្នុងបរិយាកាសច្បាប់ចម្រុះ ដោយបង្ហាញថាគេអាចចូលរួមពាក់ព័ន្ធជាមួយប្រព័ន្ធច្បាប់ចម្រុះខណៈពេលជាមួយគ្នានោះគាំទ្រដល់វប្បធម៌ទំនៀមទម្លាប់ និងការអនុវត្តក្នុងប្រទេស។

**ឧទាហរណ៍**

នៅក្នុងតំបន់អេក្វាឌ័រដែលសិទ្ធិរបស់ប្រជាជនដើមភាគតិចក្នុងការកំណត់ពីប្រព័ន្ធយុត្តិធម៌ផ្ទាល់ខ្លួនរបស់គេត្រូវមានចែងនៅក្នុងរដ្ឋធម្មនុញ្ញស្ត្រីនៅក្នុងសហគមន៍ដើមភាគតិច គិចវ៉ា (Kichwa) ពីរ បានអភិវឌ្ឍគោលការណ៍ Reglamentos de Buena Convivencia (ដែលមានន័យថាបទបញ្ញាសម្រាប់ការរស់នៅល្អ) ដែលរួមបញ្ចូលគ្នានូវបទដ្ឋានប្រពៃណីនិងគោលការណ៍សិទ្ធិមនុស្សដើម្បីដោះស្រាយអំពើហឹង្សានៅក្នុងគ្រួសារនិងលទ្ធភាពទទួលបានយុត្តិធម៌របស់ស្ត្រី។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលមានឈ្មោះថា PEKKA មានបណ្តុះបណ្តាលជំនួយការមេធាវីនៅសហគមន៍ដើម្បីគាំទ ដ្រល់ស្ត្រីក្នុងការប្រើប្រាស់តុលាការសាសនាដើម្បីចុះបញ្ជីអាពាហ៍ពិពាហ៍និងការលែងលះគ្នាដោយស្របច្បាប់ដែលជួយពួកគេឲ្យទទួលបានសេវាកម្មសាធារណៈនិងអត្ថប្រយោជន៍។ អង្គការ PEKK ក៏មានបញ្ចុះបញ្ចូលរដ្ឋាភិបាលផងដែរឲ្យបង្កើនចំនួនតុលាការនៅថ្នាក់មូលដ្ឋាននិងលើកលែងថ្លៃសេវាដើម្បីឲ្យស្ត្រីអាចប្រើប្រាស់តុលាការបានកាន់តែច្រើនថែមទៀត។

## ប្រអប់ទី១៖ ការរក្សាតុល្យភាពជញ្ជីង៖ សំណុំរឿងធំៗដែលបានផ្លាស់ប្តូរជីវិតរបស់ស្ត្រី

សំណុំរឿងទាំងនេះបានបង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ នៅក្នុងប្រទេសទាំងឡាយក្នុងពិភពលោក។ ប្រទេសខ្លះបានជំរុញឲ្យមានការយល់ដឹងអំពីសិទ្ធិមនុស្សរបស់ស្ត្រីស្របច្បាប់ ក្រោមច្បាប់អន្តរជាតិ ប្រទេសខ្លះបានអនុវត្តឬ បំភ្លឺច្បាប់ដែលមាននៅក្នុងសៀវភៅរួចទៅហើយ ប្រទេសខ្លះបានជំទាស់ជាមួយច្បាប់ដែលគួរតែត្រូវបានលុបចោល ហើយប្រទេសខ្លះទៀតបានបង្កើតច្បាប់ថ្មី។ សកម្មភាពទាំងអស់នេះបាននាំទៅរកការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងជីវិតរបស់ស្ត្រី។

**Meera Dhungana ក្នុងនាម FWLD v HMG**

នៅក្នុងប្រទេសនេប៉ាល់ច្បាប់លើកលែងបុរសពីការផ្តន្ទាទោសចំពោះការរំលោភប្រពន្ធរបស់ខ្លួន។ នៅក្នុងឆ្នាំ២០០២ ក្នុងករណីមួយដែលបានចាត់ការដោយវេទិកាសម្រាប់ស្ត្រីស្តីពីច្បាប់និងការអភិវឌ្ឍតុលាការកំពូលបានបញ្ជាឲ្យរដ្ឋសភាធ្វើវិសោធនកម្មច្បាប់ស្តីពីការរំលោភសេពសន្ថវៈ។ រហូតមកទល់ពេលនេះប្រទេសចំនួន៥២ទូទាំងសកលលោកមានដាក់ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ជាទោសឧក្រិដ្ឋយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួន។

**សាលក្រមរបស់តុលាការធម្មនុញ្ញនៃប្រទេសកូឡុំប៊ី**

នៅក្នុងឆ្នាំ២០០៦ Women's Link Worldwide បានចាត់ការ សំណុំរឿងមួយតំណាងអោយ Martha Solay ដើម្បីជំទាស់ទៅនឹងច្បាប់ដែលហាមគ្រូពេទ្យមិនឲ្យធ្វើការរំលូតកូនដើម្បីជ្រោះជីវិតរបស់នាង។ តុលាការបានកំណត់ថាការហាមប្រាមនេះរំលោភសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី និងបានបញ្ជាក់ថាការរំលូតកូនត្រូវតែអាចធ្វើឡើងនៅក្នុងករណីពិសេសមួយចំនួន។

**Unity Dow ទល់នឹង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃសាធារណរដ្ឋបូតស្វាណា (Unity Dow v Attorney General of the Republic of Botswana )**

ទោះបីជាជាពលរដ្ឋម្នាក់ដែលកើតនិងរស់នៅក្នុងប្រទេសបូតស្វាណា (Botswana) ច្បាប់បានបញ្ជាក់ថាដោយសារតែ Unity Dow បានរៀបការជាមួយជនបរទេស កូនពីរនាក់របស់ពួកគេត្រូវការលិខិតអនុញ្ញាតរស់នៅក្នុងប្រទេសនេះហើយត្រូវបានគេបដិសេធមិនផ្តល់ឲ្យនូវសិទ្ធិជាពលរដ្ឋ។ សំណុំរឿងឆ្នាំ១៩៩២ដ៏លេចធ្លោនេះ បានបញ្ជាក់ថាការធានាសមភាពនៅក្នុងរដ្ឋធម្មនុញ្ញអនុវត្តចំពោះសិទ្ធិជាពលរដ្ឋរបស់ស្ត្រី។

**Velez និងអ្នកដទៃទៀតទល់នឹងក្រុមហ៊ុនឱសថ Novartis Pharmaceuticals**

នៅក្នុងប្រភេទករណីរើសអើងយេនឌ័រធំបំផុតដែលមិនធ្លាប់មានក្នុងការជំនុំជម្រះក្តីក្នុងសហរដ្ឋអាមេរិកនិយោជិតស្រី ចំនួន១២នាក់ នៃ ក្រុមហ៊ុនឱសថណូវ៉ាទីស (Novartis) បានចោទប្រកាន់ថាពួកគេត្រូវបានគេរើសអើងទាក់ទងទៅនឹងប្រាក់ឈ្នួលនិងការដំឡើងឋានៈ។ គណៈវិនិច្ឆ័យបានរកឃើញជាឯកច្ឆន្ទដោយគាំទ្រទៅលើនិយោជិតទាំងនេះក្រុមហ៊ុនណូវ៉ាទីសបានយល់ព្រមបង់ប្រាក់ឈ្នួលចំនួន១៧៥លានដុល្លារអាមេរិកដើម្បីដោះស្រាយបញ្ហានេះរួមទាំង២២,៥លានដុល្លារសម្រាប់ការកែលំអរគោលនយោបាយនិងកម្មវិធីនានាដើម្បីលើកកម្ពស់សមភាពនៅកន្លែងធ្វើការ។

# អនុវត្តកំណែទម្រង់ច្បាប់ដែលយកចិត្តទុកដាក់នឹងយេនឌ័រ

កំណែទម្រង់ច្បាប់ដែលយកចិត្តទុកដាក់នឹងយេនឌ័រគឺជាមូលដ្ឋានគ្រឹះសម្រាប់ស្ត្រីទទួលបានយុត្តិធម៌។ ប្រសិនបើគ្មានមូលដ្ឋានគ្រឹះច្បាប់រឹងមាំមួយទេនោះការប៉ុនប៉ងធ្វើឲ្យតុលាការកាន់តែអាចប្រើប្រាស់បានដោយស្ត្រីនគរបាលមានលក្ខណៈប្រទូសរ៉ាយតិចជាងមុនចំពោះបណ្តឹងរបស់ពួកគេ និងកំណែទម្រង់ចាំចាច់ដទៃទៀតទៅលើរដ្ឋបាលយុត្តិធម៌ ទំនងជានឹងត្រូវបរាជ័យ។

CEDAW ផ្តល់ស្តង់ដារមាសដែលមានការឯកភាពគ្នាជាអន្តរជាតិ សម្រាប់កំណែទម្រង់ច្បាប់ដើម្បីសម្រេចបានសមភាពយេនឌ័រ។ គេត្រូវការវិធានការដើម្បីលុបចោលច្បាប់ ទាំងឡាយដែលរើសអើងប្រឆាំងនឹងស្ត្រីយ៉ាងច្បាស់ក្រឡែត,ដើម្បីពង្រីកនីតិរដ្ឋទៅដល់វិស័យឯកជនរួមទាំងដើម្បីការពារស្ត្រីពីអំពើហឹង្សាក្នុងគ្រួសារ និងដើម្បីដោះស្រាយផលប៉ះពាល់ជាក់ស្តែងនៃច្បាប់មកលើជីវិតរបស់ស្ត្រី។

រហូតមកទល់ពេលនេះ គេសង្កេតឃើញមានវឌ្ឍនភាពនៅក្នុងគ្រប់តំបន់ ដោយនៅក្នុងឆ្នាំ២០១១៖

- **ប្រទេសចំនួន១៧៣** ធានាដល់ការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល
- **រដ្ឋធម្មនុញ្ញចំនួន១៣៩** ធានាសមភាពយេនឌ័រ
- **ប្រទេសចំនួន១២៥** ដាក់ឲ្យអំពើហឹង្សាក្នុងគ្រួសារនៅក្រៅច្បាប់ (មើលរូបភាពទី១)
- **ប្រទេសចំនួន១១៧** មានច្បាប់ស្តីពីប្រាក់ឈ្នួលស្មើគ្នា
- **ប្រទេសចំនួន១១៥** ធានាដល់សិទ្ធិទទួលបានទ្រព្យសម្បត្តិស្មើគ្នារបស់ស្ត្រី

ប៉ុន្តែទោះបីជាមានភាពជឿនលឿនយ៉ាងច្រើនក៏ដោយច្បាប់រើសអើង ចំណុចខ្វះខាតនៅក្នុងក្របខ័ណ្ឌច្បាប់និងបរាជ័យនៃការអនុវត្ត មានន័យថាស្ត្រីនៅតែត្រូវគេបដិសេធនូវសិទ្ធិរបស់គេដដែល។

- **ប្រទេសចំនួន១២៧** មិនបានដាក់ការរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍ជាបទឧក្រិដ្ឋឲ្យបានច្បាស់លាស់ទេ
- **ប្រទេសចំនួន៦១** រឹតត្បិតយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ស្ត្រីក្នុងការរំលូតកូន
- **ស្ត្រីចំនួន៥៣ភាគរយ** ធ្វើការនៅក្នុងការងារដែលងាយរងគ្រោះ
- **ប្រទេសចំនួន៥០** មានអាយុរៀបការតាមច្បាប់សម្រាប់ស្ត្រីទាបជាងសម្រាប់បុរស
- **១០ ទៅ ៣០ភាគរយ** គឺជាគម្លាតរាក់ឈ្នួលជាមធ្យមរវាងស្ត្រីនិងបុរស

ទោះបីជា CEDAW ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិភាគច្រើនក៏ដោយក៏វាជាសន្ធិសញ្ញាមួយដែលនៅមានមន្ទិលសង្ស័យច្រើនបំផុតផងដែរ។ ភាពមិនច្បាស់លាស់ទូទៅបំផុតគឺនៅក្នុងមាត្រា ១៦ ដែលធានាសិទ្ធិស្ត្រីនៅក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ(មើលរូបភាពទី២)។ ការជម្រះនូវមន្ទិលសង្ស័យទាំងនេះគឺជាជំហានដ៏សំខាន់បំផុតមួយដើម្បីរៀបចំឲ្យមានក្របខ័ណ្ឌច្បាប់មួយដែលគាំទ្រដល់សិទ្ធិរបស់ស្ត្រី។

ច្បាប់ត្រូវតែព្រាងឡើងដើម្បីជំរុញការអនុវត្ត រួមទាំងអាណត្តិ នីតិវិធី ថវិកា និងយន្តការគណនេយ្យភាពច្បាស់លាស់ផងដែរ។ ឧទាហរណ៍នៅក្នុងប្រទេសចំនួន៩៥ច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសាររួមបញ្ចូលនូវការធានាដល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃសម្រាប់ស្ត្រី។ នៅក្នុងប្រទេសនេប៉ាល់ ការលើកលែងពន្ធលើការផ្ទេរដីធ្លីបានជួយធានាដល់ការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួលមរតកស្មើភាពដែលបានធ្វើឲ្យមានការកើនឡើងបីដងនៃកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ស្ត្រី។នៅក្នុងប្រទេសស៊ុយអែត "ខែឪពុក" ដែលមិនអាចផ្ទេរបាន បានបង្កើននូវការទទួលបានការឈប់សម្រាកបិតុភាពដោយជួយដោះស្រាយគម្លាតនៃប្រាក់ឈ្នួលដែលពាក់ព័ន្ធនឹងយេនឌ័រ។

រូបភាពទី១៖ ច្បាប់ស្តីពីអំពើហឹង្សាប្រឆាំងនឹងស្ត្រី

ពីរភាគបីនៃប្រទេសមានច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ ប៉ុន្តែប្រទេសជាច្រើននៅតែមិនបានដាក់ការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ជាទោសឧក្រិដ្ឋឲ្យបានច្បាស់នោះទេ។




ប្រភព៖ ឧបសម្ព័ន្ធទី៤ វឌ្ឍនភាពនៃស្ត្រីពិភពលោក ឆ្នាំ២០១១-២០១២

រូបភាពទី២៖ ភាពស្រពិចស្រពិល ចំពោះ CEDAW

៣០ ប្រទេសមានភាពស្រពិចស្រពិលទាក់ទងទៅនឹងសិទ្ធិស្មើគ្នានៅក្នុងអាពាហ៍ពិពាហ៍ ឬគ្រួសារ។

ចំនួនប្រទេសដែលមានភាពស្រពិចស្រពិល




ប្រភព៖ ឧបសម្ព័ន្ធទី៥ វឌ្ឍនភាពនៃស្ត្រីពិភពលោក ឆ្នាំ២០១១-២០១២

# គាំទ្រដល់ច្រកចូលតែមួយ ដើម្បីកាត់បន្ថយ ការបាត់បង់នៅក្នុង សង្វាក់យុត្តិធម៌

សង្វាក់យុត្តិធម៌ ជាជំហានមួយចំនួនដែលស្ត្រីម្នាក់ត្រូវតែចាត់ធ្វើឡើងដើម្បីស្វែងរកសំណង ត្រូវបានសម្គាល់ដោយកម្រិតដ៏ខ្ពស់នៃការបាត់បង់ ដែលក្នុងនោះសំណុំរឿងត្រូវបានគេទម្លាក់ចោលនៅពេលដែលវាឆ្លងកាត់ប្រព័ន្ធ។ ជាលទ្ធផលមានតែសំណុំរឿងមួយចំនួនតូច ប៉ុណ្ណោះដែលឈានទៅដល់ការកាត់ទោស ឬលទ្ធផលប្រកបដោយយុត្តិធម៌មួយ។

ការសិក្សាឆ្នាំ២០០៩មួយរបស់ប្រទេសអឺរ៉ុបបានរកឃើញថា ជាមធ្យម ១៤ភាគរយ នៃការរំលោភសេពសន្ថវៈ បានចប់ទៅដោយមានការកាត់ទោស ដោយមានអត្រាធ្លាក់ចុះមកទាប ត្រឹម៥ភាគរយនៅក្នុងប្រទេសខ្លះ (មើលរូបភាពទី៣)។

វិធីមួយដើម្បីកាត់បន្ថយការបាត់បង់គឺត្រូវវិនិយោគនៅក្នុងច្រកចូលតែមួយ ដែលប្រមូលផ្តុំនូវសេវាសំខាន់ៗបំផុតក្រោមដំបូលតែមួយ ដើម្បីប្រមូលភស្តុតាងវិទ្យាសាស្ត្រ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ ការថែទាំសុខភាព និងការគាំទ្រដទៃទៀតសម្រាប់ស្ត្រី។

មជ្ឈមណ្ឌល ថែទាំធូធូហ្សេឡា នៅក្នុង Thuthuzela Care Centres (TCCs) អាហ្វ្រិកខាងត្បូង គឺជាឧទាហរណ៍ជោគជ័យមួយនៃវិធីនេះ។
មជ្ឈមណ្ឌលទាំងនេះមានទីតាំងស្ថិតនៅក្នុងមន្ទីរពេទ្យសាធារណៈ និងផ្តល់ការថែទាំសង្គ្រោះបន្ទាន់ ផ្តល់ប្រឹក្សា និងការរៀបចំសម្រាប់តុលាការដែលមានលក្ខណៈសមាហរណកម្ម និងស្ទុទ្ធិស្នាលជាមួយជនរងគ្រោះ។មជ្ឈមណ្ឌលទាំងនេះមានគោលបំណងដោះស្រាយតម្រូវការសុខភាព និងសង្គមរបស់ជនរងគ្រោះដោយអំពើរំលោភផ្លូវភេទកាត់បន្ថយការធ្លាក់ខ្លួនជាជនរងគ្រោះឡើងវិញ កែលំអអត្រាកាត់ទោស និងកាត់បន្ថយការពន្យារពេលនៅក្នុងសំណុំរឿង។

មជ្ឈមណ្ឌល TCCs មានបុគ្គលិកដែលមានឯកទេសខាងវេជ្ជសាស្ត្រ សង្គមកិច្ច និងនគរបាល ដែលធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ។ អត្រាកាត់ទោសសម្រាប់ករណីរំលោភសេពសន្ថវៈដែលបានដោះស្រាយដោយមជ្ឈមណ្ឌល the Soweto TCC នៅក្នុងខេត្តហ្គូតេង បានកើនឡើងដល់៨៩ភាគរយ បើប្រៀបធៀបនឹងមធ្យមភាគទូទាំងប្រទេសដែលមាន៧ភាគរយ។ ឥឡូវនេះគំរូ Thuthuzela កំពុងត្រូវបានចម្លងតាមនៅក្នុងប្រទេសដទៃទៀត ក្នុងនោះរួមទាំងឈីលី និងអេត្យូពី ផងដែរ។

រូបភាពទី៣៖ ការបាត់បង់សំណុំរឿងរំលោភសេពសន្ថវៈនៅក្នុងប្រទេសអឺរ៉ុបមួយចំនួនក្នុងសំណាកដែលបានជ្រើសរើសមកសិក្សា

មានតែសំណុំរឿងរំលោភសេពសន្ថវៈមួយចំនួនតូចប៉ុណ្ណោះដែលបានទទួលការកាត់ទោស។




ប្រភព៖ Lovett និង Kelly 2009.

## ដាក់ស្ត្រីនៅជួរមុខនៃការអនុវត្តច្បាប់

ការរាយការណ៍មិនគ្រប់គ្រាន់អំពីបទល្មើសប្រឆាំងនឹងស្ត្រីគឺជាបញ្ហាធ្ងន់ធ្ងរមួយនៅគ្រប់តំបន់។ នៅក្នុងប្រទេសចំនួន៥៧ ការអង្កេតលើបទល្មើសបង្ហាញថា ស្ត្រីជាមធ្យម ១០ភាគរយ និយាយថាពួកគេបានទទួលរងនូវការរំលោភផ្លូវភេទ ប៉ុន្តែក្នុងចំណោមអ្នកទាំងនេះ មានតែ១១ភាគរយប៉ុណ្ណោះដែលបានរាយការណ៍ឲ្យគេដឹង។ បើប្រៀបធៀបនឹងឧប្បត្តិហេតុនៃការលួចប្លន់ ជាមធ្យម៨ភាគរយៈ ប៉ុន្តែអត្រារាយការណ៍គឺមាន៣៨ភាគរយ។

ការផ្តល់ការងារដល់ស្ត្រីនៅជួរមុខនៃការផ្តល់សេវាយុត្តិធម៌ អាចជួយបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌។ ទិន្នន័យបង្ហាញថា មានទំនាក់ទំនងជាវិជ្ជមានមួយរវាងវត្តមាននៃមន្ត្រីនគរបាលជាស្ត្រី និងការរាយការណ៍អំពីការរំលោភផ្លូវភេទ (មើលរូបភាពទី៩)។នៅក្នុងតំបន់លីបេរីយ៉ា ក្រោយពេលមានជម្លោះការដាក់ពង្រាយកងកម្លាំងនគរបាលឥណ្ឌាជាស្ត្រីទាំងអស់បានធ្វើឲ្យមានការកើនឡើងនូវការរាយការណ៍ និងបានជំរុញដល់ការជ្រើសរើសស្ត្រីចូលបម្រើក្នុងកងកម្លាំងនគរបាលផងដែរ។ ទោះបីជាមានអត្ថប្រយោជន៍ទាំងនេះក៏ដោយភាពជាតំណាងជាមធ្យមរបស់ស្ត្រីនៅក្នុងនគរបាលនៅក្នុងតំបន់នីមួយៗ គឺ មិនលើសពី ១៣ភាគរយទេ។ ផលចំណេញដែលបានមកពីការផ្តល់ការងារដល់ស្ត្រីនៅក្នុងជួរនគរបាល មិនមែនដោយស្វ័យប្រវត្តិនោះទេ៖ ការវិនិយោគគឺជាការកត្តាសំខាន់ជាសារវ័ន្ត។ បទពិសោធន៍ពីទ្វីបអាមេរិកឡាទីន និងទីកន្លែងផ្សេងទៀត គឺថាប៉ុស្តិ៍នគរបាលស្ត្រីនិងកន្លែងធ្វើការងារយេនឌ័រត្រូវតែមានធនធានគ្រប់គ្រាន់ហើយបុគ្គលិកគួរទទួលការបណ្តុះបណ្តាលជំនាញផ្តល់រង្វាន់ជូនដោយសមស្រប និងទទួលស្គាល់ចំពោះស្នាដៃការងាររបស់ពួកគេ។

បន្ថែមពីលើនេះ ការជ្រើសរើសមន្ត្រីនគរបាលជាស្ត្រី និងការផ្តល់ធនធាន កន្លែងធ្វើការងារយេនឌ័រ ត្រូវតែជាផ្នែកមួយនៃយុទ្ធសាស្ត្រទូលំទូលាយមួយដើម្បីបណ្តុះបណ្តាល និងផ្តល់គ្រឿងលើកទឹកចិត្តដល់នគរបាលទាំងអស់ដើម្បីឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់ស្ត្រី។

## វិនិយោគនៅក្នុងលទ្ធភាពទទួលបានយុត្តិធម៌របស់ស្ត្រី

ការធ្វើឲ្យប្រព័ន្ធយុត្តិធម៌ធ្វើការសម្រាប់ស្ត្រី ទោះជាតាមរយៈការជំរុញកំណែទម្រង់ច្បាប់ ឬការគាំទ្រជំនួយផ្នែកច្បាប់ច្រកចូលតែមួយ និងការបណ្តុះបណ្តាលសម្រាប់ចៅក្រម សុទ្ធតែត្រូវការការវិនិយោគទាំងអស់។ ការទទួលស្គាល់ពីសារៈសំខាន់នៃការពង្រឹងនីតិរដ្ឋ រដ្ឋាភិបាលចំណាយយ៉ាងច្រើនទៅលើជំនួយផ្នែកយុត្តិធម៌។ ទោះបីជាយ៉ាងណាក្តី ថវិកាសម្រាប់គាំទ្រសមភាពយេនឌ័រនៅតែទាបដដែល។ នៅក្នុងឆ្នាំ២០០៩ ម្ចាស់ជំនួយនៅលើគណៈកម្មាធិការជំនួយអភិវឌ្ឍន៍នៃអង្គការសម្រាប់សហប្រតិបត្តិការនិងការអភិវឌ្ឍសេដ្ឋកិច្ច (OECD-DAC) បានធ្វើវិភាជន៍ថវិកាចំនួន ៤,២ពាន់លានដុល្លារដល់វិស័យយុត្តិធម៌ដោយក្នុងនោះ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបរួមគ្នាផ្តល់ដល់ទៅ៧០ភាគរយនៃថវិកាសរុបនេះ។ អ៊ីរ៉ាក់ អាហ្វហ្គានីស្ថាន ម៉ិកស៊ិកូ ទឹកដីប៉ាលេស្ទីន និងប៉ាគីស្ថាន គឺជាប្រទេសដែលទទួលជំនួយនេះច្រើនជាងគេបំផុត។ នៅក្នុងចំនួនសរុបនេះ ថវិកាចំនួន២០៦លានដុល្លារ (៥ភាគរយ) ត្រូវបានធ្វើវិភាជន៍សម្រាប់កម្មវិធីនានាដែលមានសមភាពយេនឌ័រ ជាគោលបំណងទីមួយ។ ថវិកាចំនួន ៦៣៣លានដុល្លារបន្ថែមទៀត (១៥ភាគរយ) ត្រូវបានបែងចែកទៅកម្មវិធីនានាដែលមានសមភាពយេនឌ័រជាគោលបំណងទីពីរ។ សហភាពអឺរ៉ុបពុំបានបែងចែកដល់កម្មវិធីយុត្តិធម៌ ដែលមានសមភាពយេនឌ័រជាគោលបំណងទីមួយក្នុងឆ្នាំ២០០៩ឡើយ។ ស៊ុយអែត កាណាដា ដាណឺម៉ាក ន័រវេ និងអាល្លឺម៉ង់ គឺជាប្រទេសផ្តល់ជំនួយធំបំផុតសម្រាប់កម្មវិធីទាំងឡាយដែលសមភាពយេនឌ័រគឺជាគោលបំណងចម្បងទីមួយ ដោយគាំទ្រសកម្មភាពនានារួមទាំងការបណ្តុះបណ្តាលសម្រាប់ចៅក្រមជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយអំពើហិង្សា ការចូលរួមរបស់ស្ត្រីនៅក្នុងការកសាងសន្តិភាព និងការបង្រួបបង្រួមជាតិ ការធ្វើសមាហរណកម្មឡើងវិញនៃជនរងគ្រោះដោយអំពើជួញដូរនិងយុទ្ធនាការលើកកម្ពស់ការយល់ដឹងដើម្បីកាត់បន្ថយការរៀបការក្មេងពេក។ ខ្វាតាមេឡា ប៊ីគីណា ហ្វាសូ សាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ អាហ្វហ្គានីស្ថាននិងកូឡុំប៊ី បានទទួលជំនួយផ្នែកយុត្តិធម៌ដែលផ្តោតទៅលើសមភាពយេនឌ័រច្រើនបំផុតក្នុងឆ្នាំ២០០៩។

រូបភាពទី៩៖ ស្ត្រីនៅក្នុងនគរបាលនិងការរាយការណ៍អំពីការរំលោភផ្លូវភេទ




ប្រភព៖ ការវិភាគរបស់អង្គការ UN Women ដោយផ្អែកលើទិន្នន័យនៃភាពជាតំណាងក្នុងជួរនគរបាលពី UNODC 2009 និងការរាយការណ៍អំពីការរំលោភផ្លូវភេទ គណនាចេញពី ICVS (ចុងក្រោយបំផុត)។

ក្នុងកំឡុងទសវត្សរ៍ ពីឆ្នាំ២០០០ ដល់ ២០១០ធនាគារពិភពលោកបានធ្វើវិភាជន៍ថវិកាចំនួន៨៧៤ពាន់លានដុល្លារ ដល់គម្រោងចំនួន៦,៣៨២គម្រោងនិងថវិកាជំនួយឥតសំណង ដែលក្នុងនោះ ១២៦ ពាន់លានដុល្លារ (១៤ភាគរយ) ត្រូវបានបែងចែកទៅឲ្យរដ្ឋបាលសាធារណៈ ច្បាប់ និងយុត្តិធម៌។ នៅក្នុងរយៈពេលនេះគម្រោងចំនួន២១ បានរួមបញ្ចូលនូវផ្នែកសមភាពយេនឌ័រ និងនីតិរដ្ឋ ដោយគាំទ្រសកម្មភាពនានា ដូចជា ការកែលំអហេដ្ឋារចនាសម្ព័ន្ធតុលាការដែលឆ្លើយតបនឹងស្ត្រី ការជ្រើសរើសនិងការកសាងសមត្ថភាពរបស់ជំនួយការមេធាវី និងការតស៊ូមតិគោលនយោបាយសម្រាប់កំណែទម្រង់ច្បាប់។ ថវិកាសរុបដែល បានបែងចែកទៅឲ្យផ្នែកសមភាពយេនឌ័រនៃគម្រោងទាំងនេះ មានចំនួនតែ៧.៣លានដុល្លារ ប៉ុណ្ណោះ។

នៅក្នុងខែធ្នូ ឆ្នាំ២០១០ ធនាគារពិភពលោកបានបញ្ចប់ដំណើរការបំពេញឡើងវិញនូវថវិការបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ដោយក្នុងនោះម្ចាស់ជំនួយចំនួន៥១ បានសន្យាផ្តល់៤៩.៣ពាន់លានដុល្លារដើម្បីគាំទ្រដល់ប្រទេសក្រីក្របំផុតពីឆ្នាំ២០១១ដល់ ២០១៤។ នៅក្នុងជុំនេះ ផ្នែកពិសេសចំនួនបួនត្រូវបានឯកភាពដែលក្នុងនោះមានសមភាពយេនឌ័រមួយផងដែរ។ នេះគឺជាឱកាសដែលល្អបំផុតដើម្បីធានាថាលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ ទទួលបានចំណែកកាន់តែច្រើននៃថវិការបស់ធនាគារពិភពលោកនាពេលអនាគត។

## បណ្តុះបណ្តាលចៅក្រម និង តាមដានមើលការសម្រេចចិត្ត

ការធ្វើការសម្រេចចិត្តប្រកបដោយតុល្យភាព មានព័ត៌មានគ្រប់គ្រាន់ និងមិនលំអៀង គឺជាផ្នែកសារវ័ន្តមួយនៃការធានាថាស្ត្រីដែលទៅរកតុលាការទទួលបានយុត្តិធម៌។ ទោះបីជាយ៉ាងណាក្តី សូម្បីតែនៅទីណាដែលមានច្បាប់នៅនឹងកន្លែង ដើម្បីធានាសិទ្ធិស្ត្រីក៏ដោយ ក៏ច្បាប់ទាំងនេះមិនតែងតែត្រូវបានអនុវត្តដោយត្រឹមត្រូវឬដោយស្មើភាពដែរ។ អង្គការនានា ដូចជាសមាគមអន្តរជាតិនៃចៅក្រមស្ត្រី និងសាក់ស្ហី (Sakshi) ដែលជាអង្គការក្រៅរដ្ឋាភិបាលឥណ្ឌាមួយ ផ្តល់ដល់ចៅក្រមទាំងស្រីទាំងប្រុស នូវការបណ្តុះបណ្តាលជំនាញ និងឱកាសដើម្បីពិភាក្សា អំពីបញ្ហាប្រឈមដែលពួកគេជួបប្រទះដែលអាចជួយបង្កើនការយល់ដឹង និងការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ។ ផលប៉ះពាល់នៃការងារនេះគឺត្រូវបានបង្ហាញ តាមរយៈសំណុំរឿងដំបូងៗជាច្រើនដែលត្រូវបានសម្រេចដោយចៅក្រមដែលបានចូលរួមនៅក្នុងការបណ្តុះបណ្តាលទាំងនេះ(មើលប្រអប់ទី២)។ ការតាមដានជាលក្ខណៈប្រព័ន្ធនៃការធ្វើការសម្រេចចិត្តរបស់តុលាការគឺជាការចាំបាច់នៅថ្នាក់ជាតិដើម្បីផ្តល់គណនេយ្យភាពដល់ស្ត្រីដែលស្វែងរកយុត្តិធម៌ និងដើម្បីជួយសង្គមស៊ីវិលនិងរដ្ឋាភិបាលតាមដានមើលទង្វើរបស់តុលាការទៅលើសិទ្ធិរបស់ស្ត្រី។

### ប្រអប់ទី២៖ វីស្ហាកា (Vishaka) និងអំណាចនៃការធ្វើការសម្រេចចិត្តរបស់តុលាការដោយយកចិត្តទុកដាក់ នឹងយេនឌ័រ

នៅក្នុងឆ្នាំ១៩៩៦អង្គការក្រៅរដ្ឋាភិបាលឥណ្ឌា ឈ្មោះ សាកស្ហី (Sakshi) បានធ្វើសម្ភាសន៍ជាមួយចៅក្រម មេធាវី និងដើមបណ្តឹងជាស្ត្រីដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការយល់ឃើញ និង ការសម្រេចចិត្តរបស់តុលាការមកលើស្ត្រីដែលចូលមករកតុលាការ។ ជាងពីរភាគបីនៃចៅក្រមបាននិយាយថាស្ត្រីដែលស្លៀកពាក់សំលៀកបំពាក់លេចលើលេចក្រោម ធ្វើឲ្យទាក់ទាញដល់ការរំលោភសេពសន្ថវៈ។

អង្គការ សាកស្ហី បានអភិវឌ្ឍកម្មវិធីមួយដើម្បីផ្លាស់ប្តូរជំនឿខាងក្នុងនិងផ្នត់គំនិត យេនឌ័រ ដែលរហូតមកទល់ពេលនេះបានពង្រីកទៅដល់១៦ប្រទេស ក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក។ អតីតប្រធានចៅក្រមរបស់ប្រទេស ឥណ្ឌា ឈ្មោះ Jagdish Sharan Verma គឺជាសិក្ខាកាមដំបូងបំផុតម្នាក់នៅក្នុងកម្មវិធីនេះ។ ភ្លាមៗបន្ទាប់មក ចៅក្រម Verma មានឱកាសអនុវត្តផ្ទាល់នូវអ្វីដែលគាត់បានសិក្សារៀនសូត្រ។ នៅពេលនាង Bhanwari Devi ត្រូវបានរំលោភបូកដោយបុរសនៅមូលដ្ឋាន ខណៈពេលដែលនាងកំពុងធ្វើការរបស់នាងជាបុគ្គលិកសង្គមកិច្ចនៅក្នុងភូមិមួយក្នុងស្រុក Rajasthan នាងមិនត្រឹមតែចាប់ផ្តើមនូវដំណើរ ការក្តីព្រហ្មទណ្ឌប៉ុណ្ណោះទេប៉ុន្តែថែមទាំងស្វែងរកដំណោះស្រាយធំជាងនេះសម្រាប់ស្ត្រីដែល ធ្វើការផ្សេងៗទៀតផងដែរ។ ដោយមានការគាំទ្រ ពីអង្គការស្ត្រីចំនួន៥រួមទាំងអង្គការមួយឈ្មោះ វីស្ហាកា (Vishaka) និង ណៃណា កាពួរ (Naina Kapur) ស្ថាបនិករបស់អង្គការ Sakshi និងទីប្រឹក្សាច្បាប់នាំមុខ Bhanwari បានបញ្ជូនសំណុំរឿងទៅតុលាការកំពូលឥណ្ឌា។

ទីនេះពួកគេទទួលបាននូវការទទួលស្គាល់ដ៏ធំអំពីការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។ ក្នុងនាមជាចៅក្រមជំនុំជម្រះមួយរូបនៅក្នុងសំណុំរឿងនេះ ចៅក្រម Verma មិនបានត្រូវរារាំងដោយអវត្តមានច្បាប់ស្តីពីការបៀតបៀនផ្លូវភេទនោះឡើយ ដោយទទួលស្គាល់ថាសិទ្ធិក្នុងការទទួលបានសមភាពយេនឌ័រ និងទទួលបានបរិស្ថានការងារប្រកបដោយសុវត្ថិភាព ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសឥណ្ឌាក្រោមអនុសញ្ញា CEDAW ។ តុលាការបានប្រើប្រាស់សំណុំរឿងនេះដើម្បីបង្កើតគោលការណ៍ណែនាំដែលអាចអនុវត្តបានតាមច្បាប់គ្រប់ជ្រុងជ្រោយដំបូងបំផុតស្តីពីការបៀតបៀនផ្លូវភេទសម្រាប់ការងារទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ការសម្រេចចិត្តរបស់អង្គការ Vishaka បានញ៉ាំងឲ្យមានសំណុំរឿងស្រដៀងគ្នាមួយនៅក្នុងប្រទេសបង់ក្លាដែស និងកំណែទម្រង់ច្បាប់នៅក្នុងប្រទេសប៉ាគីស្ថាន ដូច្នេះបច្ចុប្បន្ននេះស្ត្រីជិត៥០០លាននាក់ដែលស្ថិតក្នុងវ័យធ្វើការងារនៅក្នុងប្រទេសទាំងនេះទទួលបានការគាំពារផ្នែកច្បាប់ដែលត្រូវការដើម្បីធ្វើការងាររបស់ពួកគេដោយគ្មានការបៀតបៀន និងការរំលោភ។

## បង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទៅរកតុលាការ និងគណៈកម្មការស្វែងរកការពិតក្នុងពេល និងក្រោយជម្លោះ

អំពើហឹង្សាផ្លូវភេទជាកលយុទ្ធនៃសង្គ្រាមមួយត្រូវបានគេប្រើប្រាស់ជាលក្ខណៈប្រព័ន្ធនិងដោយចេតនាអស់រយៈពេលជាច្រើនសវត្សមកហើយ។ វាត្រូវបានគេប្រើប្រឆាំងនឹងប្រជាជនស៊ីវិលជាភ្នាក់ងារ ដោយចេតនាមួយនៃមេរោគអេដស៍សម្រាប់គោលបំណងឲ្យមានផ្ទៃពោះដោយបង្ខំដើម្បីជំរុញឲ្យមានការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងដើម្បីបន្លាចសហគមន៍ទាំងមូល។

ភាពជឿនលឿនជាច្រើននៅក្នុងច្បាប់អន្តរជាតិក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ បានធ្វើឲ្យគេអាចផ្តន្ទាទោសជាលើកដំបូងនូវបទឧក្រិដ្ឋអំពើហឹង្សាផ្លូវភេទ (មើលប្រអប់ទី៣)។ ដើម្បីបង្កើនចំនួននៃការដាក់ទោស ជាការសំខាន់ណាស់ដែលតុលាការអន្តរជាតិ កំណត់អាទិភាពបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងយេនឌ័រ ក្នុងយុទ្ធសាស្រ្តផ្តន្ទាទោសរបស់ខ្លួន។
បន្ថែមពីលើនេះ គេត្រូវការវិធានការដើម្បីធ្វើឲ្យស្ត្រីកាន់តែអាចប្រើបានច្រើនថែមទៀតនូវតុលាការ ក៏ដូចជាវេទិកាយុត្តិធម៌ដទៃទៀតដូចជាគណៈកម្មការស្វែងរកការពិត។

វិធីតែមួយគត់ដែលធានាគោលបំណងនេះ គឺត្រូវធានាថាស្ត្រីដើរតួនាទីកណ្តាលមួយនៅក្នុងការកំណត់វិសាលភាពដែនកំណត់ និងការតាក់តែងគ្រប់យន្តការយុត្តិធម៌ក្រោយពេលមានជម្លោះ។

## ប្រអប់ទី៣៖ ពីរទសវត្សរ៍នៃវឌ្ឍនភាពដំបូងនៅក្នុងច្បាប់អន្តរជាតិ

កន្លងមក ផលប៉ះពាល់នៃជម្លោះមកលើស្ត្រីត្រូវបានទទួលស្គាល់តិចតួចប៉ុណ្ណោះ នៅក្នុងច្បាប់អន្តរជាតិ។ ជាលទ្ធផល បទពិសោធន៍របស់ស្ត្រីត្រូវបានបដិសេធភាគច្រើន និងសរសេរក្រៅប្រវត្តិសាស្រ្ត។ ទោះបីជាយ៉ាងណាក្តី ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ភាពជឿនលឿនយ៉ាងច្រើនត្រូវបានធ្វើឡើងនៅក្នុងការទទួលស្គាល់និងការផ្តន្ទាទោសដល់បទឧក្រិដ្ឋអំពើហឹង្សាផ្លូវភេទដែលបានប្រព្រឹត្តឡើងនៅក្នុងកំឡុងពេលមានជម្លោះ។

នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩២៩ អំពើហឹង្សាផ្លូវភេទត្រូវបានគេចាត់ទុកថាជាបញ្ហាដែលបង្ខូចសីលធម៌ជាជាងបទឧក្រិដ្ឋហឹង្សាមួយ។ធម្មនុញ្ញរបស់សាលាក្តីនូរឹមបឺហ្គ និងតូក្យូដែលបានបង្កើតឡើងដើម្បីដាក់ទោសដល់ឧក្រិដ្ឋកម្មសង្គ្រាមបន្ទាប់ពីសង្គ្រាមលោកលើកទីពីរមិនបានដាក់បញ្ចូលការរំលោភសេពសន្ថវៈនោះទេ។ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បានបញ្ជាក់ថា "ស្ត្រីនឹងត្រូវបានការពារជាពិសេសទប់ទល់នឹងការវាយប្រហារលើកិត្តិយសរបស់ពួកគេ" ប៉ុន្តែការរំលោភសេពសន្ថវៈមិនត្រូវបានរៀបរាប់ថាជា"ការរំលោភធ្ងន់ធ្ងរ"មួយនៃអនុសញ្ញានេះទេ។

### ១៩៩៣

• តុលាការព្រហ្មទណ្ឌ អន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ត្រូវបានបង្កើតឡើង។ ច្បាប់បានទទួលស្គាល់ ថាការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋ កម្មមួយប្រឆាំងនឹងមនុស្សជាតិ និងសំណុំរឿងធំៗមួយចំនួនបានបញ្ជាក់ថាអំពើហឹង្សាផ្លូវភេទគឺជាឧក្រិដ្ឋកម្មសង្គ្រាម ធ្ងន់ធ្ងរមួយ។ រហូតមកទល់ពេលនេះ មានការដាក់ទោសចំនួន២៩ករណីសម្រាប់អំពើហឹង្សាផ្លូវភេទនៅក្នុងតុលាការនេះ។

### ១៩៩៨

• នៅក្នុងករណី Prosecutor v Akayesu នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា គេឃើញថាការរំលោភរួមមានអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិជាលើកដំបូង។ រហូតមកទល់ពេលនេះ មានការកាត់ទោសចំនួន១១ករណីសម្រាប់អំពើហឹង្សាផ្លូវភេទនៅក្នុងតុលាការនេះ។

### ២០០០

• សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ បានទទួលស្គាល់តួនាទីរបស់ស្ត្រីនៅក្នុងការកសាងសន្តិភាព ដោយសង្កត់ធ្ងន់លើតម្រូវការឲ្យមានការចូលរួមពីពួកគេ នៅក្នុងគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីលើកកម្ពស់សន្តិភាពនិងសន្តិសុខ។

### ២០០២

• លក្ខន្តិកៈក្រុងរ៉ូម ដែលបានបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ បកស្រាយជាឧក្រិដ្ឋកម្មអន្តរជាតិ ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងផ្លូវភេទនិងយេនឌ័រជាច្រើន។ ក្នុងចំណោមការចោទប្រកាន់ទាំង២៣ករណីដែលចេញដោយតុលាការនេះ ១២ករណីគឺជាការចោទប្រកាន់អំពើហឹង្សាផ្លូវភេទ។

• នៅក្នុងសំណុំរឿង Prosecutor v Brima et al., តុលាការពិសេសសម្រាប់ សេរ៉ាលីអូន បានរកឃើញថាការរៀបការដោយបង្ខំគឺជាអំពើអមនុស្សធម៌ដែលជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិ។

### ២០០៨-២០១០

• សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៨២០ បានអំពាវនាវឲ្យមានវិធានការដោយប្រសិទ្ធភាពដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហឹង្សាផ្លូវភេទ ជាផ្នែករួមមួយនៃការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។
សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៨៨៨, ១៨៨៩ និង ១៩៦០ ផ្តល់នូវមូលដ្ឋានគ្រឹះជាក់ស្តែងសម្រាប់ការអនុវត្តសេចក្តីសម្រេចចិត្តលេខ ១៣២៥ និង ១៨២០។

វិធានការដែលធ្វើឲ្យមានការផ្លាស់ប្តូរ រួមមានជំនួយហិរញ្ញវត្ថុ ការថែទាំកុមារ និងការដឹកជញ្ជូន ដើម្បីជួយស្ត្រី ជំនះនូវឧបសគ្គជាក់ស្តែងចំពោះការចូលរួមរបស់ពួកគេ ការផ្តល់ប្រឹក្សាចិត្តសង្គម ការថែទាំសុខភាព និងការគាំទ្ររយៈពេលវែងផ្សេងទៀត និងការផ្តល់សវនាការបិទទ្វារដើម្បីជួយស្ត្រីធ្វើសក្ខីកម្មអំពីអំពើហឹង្សាផ្លូវភេទ។

នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តុលាការចល័តកំពុងនាំយុត្តិធម៌មក ឲ្យស្ត្រីដោយឆ្លើយតបយ៉ាងរហ័ស ដើម្បីស៊ើបអង្កេតនិងផ្តន្ទាទោសដល់អ្នកប្រព្រឹត្ត។ នៅក្នុងឆ្នាំ២០១០ តុលាការចល័តចំនួន៩ បានធ្វើការកាត់សេចក្តីចំនួន១៨៦សំណុំរឿង។ ក្នុងចំណោមសំណុំរឿងទាំងនេះ ១១៥គឺជាករណីរំលោភសេពសន្ថវៈដែលបាននាំមកនូវការដាក់ទោសចំនួន៩៥ករណី ក្នុងនោះទោសដោយដាក់ពន្ធនាគារមានពី៣ ទៅ២០ឆ្នាំ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១១ តុលាការមួយបានផ្តន្ទាទោសបទល្មើសដំបូងប្រឆាំងនឹងសំណុំរឿងមនុស្សជាតិនៅក្នុងតុលាការចល័ត ដោយបានដាក់ទោសទាហាន ចំនួន៩នាក់ពីបទចូលរួមនៅក្នុងការរំលោភសេពសន្ថវៈដ៏ច្រើនសន្ធឹកសន្ធាប់ទៅលើស្ត្រីនិងក្មេងស្រីជាង៥០នាក់ ដែលបានប្រព្រឹត្តនៅក្នុងតំបន់ Fizi ទើបតែពីរបីសប្តាហ៍មុននោះ។

# អនុវត្តកម្មវិធីផ្តល់សំណងឆ្លើយតបនឹងយេនឌ័រ

សំណងគឺជាយន្តការយុត្តិធម៌ដែលផ្តោតទៅលើជនរងគ្រោះបំផុតនិងអាចជាមធ្យោបាយសារវ័ន្តមួយសម្រាប់ការជាសះស្បើយរបស់ស្ត្រី។នៅក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាលក៏ដូចជាបរិបទក្រោយជម្លោះជាច្រើនផងដែរ ស្ត្រីនិយាយថាការផ្តល់សំណងគឺជាការចាំបាច់ដើម្បីជួយពួកគេឲ្យទទួលបានមកវិញនូវការបាត់បង់និងកាត់បន្ថយភាពក្រីក្រប៉ុន្តែវាក៏សំខាន់ដើម្បីទទួលស្គាល់ភាពឈឺចាប់របស់ស្ត្រីផងដែរ (មើលរូបភាពទី៥)។

រូបភាពទី៥៖ ទស្សនៈរបស់ស្ត្រីនិងបុរសអំពីសារៈសំខាន់នៃការផ្តល់សំណងសំខាន់នៅក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាល

ស្ត្រីទំនងជាទាមទារច្រើនជាងបុរសឲ្យមានការសុំទោសនិងការដាក់ទណ្ឌកម្មចំពោះអ្នកដែលទទួលខុសត្រូវចំពោះការរំលោភ




ប្រភព៖ ផ្អែកលើទិន្នន័យពី Vinck និង Pham 2010a and 2010b.

ទោះបីជាសហគមន៍អន្តរជាតិបានប្តេជ្ញាចិត្តផ្តល់ថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់តុលាការអន្តរជាតិ និងយន្តការអន្តរកាលផ្សេងៗទៀតក៏ដោយ ក៏វាមិនបានសមស្របទៅនឹងការប្តេជ្ញាចិត្តស្មើភាពមួយ ដើម្បីជួយរដ្ឋនានាក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនសម្រាប់សំណងយុត្តិធម៌នោះឡើយ។

ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី កម្មវិធីផ្តល់សំណងត្រូវតែពិចារណាអំពីគ្រប់ទម្រង់នៃអំពើហឹង្សាដែលពាក់ព័ន្ធនឹងផ្លូវភេទនិងយេនឌ័រ និងរួមបញ្ចូលនូវវិធានការបុគ្គល សហគមន៍ និងនិមិត្តរូប ក៏ដូចជាលទ្ធភាពទទួលបានសេវាកម្ម និងការប្រគល់ដីធ្លីមកវិញផងដែរ។

នៅក្នុងប្រទេសសេរ៉ាលីអូន គណៈកម្មការជាតិសម្រាប់សង្គមកិច្ចរបស់រដ្ឋាភិបាល ដែលគាំទ្រដោយមូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីបញ្ចប់អំពើហឹង្សាប្រឆាំងនឹងស្ត្រី និងមូលនិធិកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ (UN Trust Fund to End Violence against Women and UN Peacebuilding Fund) កំពុងអនុវត្តកម្មវិធីផ្តល់សំណងមួយដោយផ្តោតគោលដៅទៅលើស្ត្រីចំនួន៦៥០នាក់ ដែលជាជនរងគ្រោះដោយអំពើហឹង្សាផ្លូវភេទសំដៅជំរុញការផ្តល់សិទ្ធិអំណាចរយៈពេលវែងដល់ពួកគេ។

រហូតមកទល់ពេលនេះស្ត្រីចំនួន៣០០នាក់ ត្រូវបានផ្តល់ជូននូវថវិកាជំនួយឥតសំណងតូចៗ ការគាំទ្រដើម្បីបង្កើតអាជីវកម្មតូចៗ និងការបណ្តុះបណ្តាលជំនាញនៅក្នុងស្រុកចំនួន១៤ក្នុងប្រទេសនេះ។ នៅក្នុងខែមិនា ឆ្នាំ២០១១ នៅឯពិធីមួយក្នុងទីក្រុង Freetown ស្ត្រីចំនួន៩០នាក់បានបញ្ចប់វគ្គបណ្តុះបណ្តាលនានា រួមមាន អក្ខរកម្ម ការបើកបរ ជំនាញកំព្យូទ័រ ការធ្វើសាប៊ូ និង អ៊ុតសក់។

# ប្រើកូតាដើម្បីបង្កើនចំនួនអ្នកតាក់តែងច្បាប់ជាស្ត្រី

នៅក្នុងប្រទេសនានាដែលភាពជាតំណាងរបស់ស្ត្រីនៅក្នុងរដ្ឋសភាកើនឡើងយ៉ាងច្រើនច្បាប់ថ្មីៗដែលលើកកម្ពស់សិទ្ធិស្ត្រីក៏កើតឡើងច្រើនដែរ។

ពីប្រទេសនេប៉ាល់ ដល់កូស្តារីកា រវ៉ាន់ដា ដល់អេស្ប៉ាញដែលកូតាត្រូវបានគេប្រើប្រាស់ដើម្បីបង្កើនចំនួនអ្នកតាក់តែងច្បាប់ជាស្ត្រីច្បាប់បន្តបន្ទាប់ស្តីពីសិទ្ធិដីធ្លី អំពើហឹង្សាប្រឆាំងនឹងស្ត្រីការថែទាំសុខភាព និងការងារត្រូវបានអនុម័ត។ នៅទីណាដែលស្ត្រីបានចងក្រងគ្នាជូនកាលនៅទូទាំងខ្សែបណ្តោយរបស់គណបក្ស ដើម្បីធានាថាផលប្រយោជន៍របស់ស្ត្រីត្រូវបានតំណាងឲ្យការផ្លាស់ប្តូរក៏កើតមានផងដែរ។

វេទិកាទីក្រុងប៉េកាំងសម្រាប់សកម្មភាព (The Beijing Platform for Action) បានអំពាវនាវឲ្យមានតុល្យភាពយេនឌ័រនៅក្នុងស្ថាប័នរដ្ឋាភិបាល ចំណែកឯអនុសញ្ញា CEDAW តម្រូវឲ្យមានការប្រើវិធានការពិសេសបណ្តោះអាសន្នរួមទាំងកូតាផងដែរដើម្បីបង្កើនសម្លេងរបស់ស្ត្រីនៅក្នុងការធ្វើការសម្រេចចិត្ត។ក្នុងចំណោមប្រទេសទាំង២៨ដែលបានឈានដល់ឬសម្រេចបានហួសពីភាពជាតំណាងរបស់ស្ត្រី៣០ភាគរយនៅក្នុងសភាជាតិយ៉ាងតិច២៣ប្រទេសបានប្រើប្រាស់កូតា។

ថ្មីៗនេះប្រទេសចំនួន៦បានសម្រេចលើស៣០ភាគរយចេញពីជម្លោះដែលនេះបង្ហាញថាវឌ្ឍនភាពគឺពាក់ព័ន្ធទៅនឹងឆន្ទៈនយោបាយច្រើនជាងកម្រិតនៃការអភិវឌ្ឍ។ ប្រទេសមួយគឺ រវ៉ាន់ដា មានកម្រិតនៃភាពជាតំណាងរបស់ស្ត្រីដ៏ខ្ពស់បំផុតក្នុងពិភពលោក(មើលរូបភាពទី៦)។

រដ្ឋធម្មនុញ្ញឆ្នាំ២០០៣របស់ ប្រទេសរវ៉ាន់ដាធានាថាស្ត្រីត្រូវបានផ្តល់ជូននូវមុខតំណែងយ៉ាងតិច៣០ភាគរយនៅក្នុងស្ថាប័នដែលធ្វើការសម្រេចចិត្តហើយនៅក្នុងការបោះឆ្នោតក្នុងឆ្នាំដដែលនោះស្ត្រីបានសម្រេចហួសពីគោលដៅចំណុចអប្បបរមានេះទៅទៀត។សមាជិកសភាជាស្ត្រីរបស់ប្រទេសរវ៉ាន់ដាបានធ្វើការនៅក្នុងគណបក្សចម្រុះនិងបានសហការជាមួយក្រសួងកិច្ចការនារី និងអង្គការ សង្គមស៊ីវិលដើម្បីជំរុញឲ្យមានកំណែទម្រង់ រួមមាន មរតក សិទ្ធិដីធ្លីនិងអំពើហឹង្សាប្រឆាំងនឹងស្ត្រី។ សមាជិកសភាជាស្ត្រីក៏បានសហការជាមួយសហសេវិកជាបុរសផងដែរដើម្បីធ្វើការនៅទូទាំងប្រទេសដើម្បីតាមដានមើលការអនុវត្តច្បាប់ស្តីពីដីធ្លីនិងមរតកនិងដើម្បីជួយផ្លាស់ប្តូរអាកប្បកិរិយាមកលើសិទ្ធិស្ត្រី។

រូបភាពទី៦៖ ភាពជាតំណាងរបស់ស្ត្រីនិងកំណែទម្រង់ច្បាប់នៅក្នុងប្រទេសរវ៉ាន់ដា

ច្បាប់ស្តីពីសិទ្ធិស្ត្រី មានការរីកចំរើនបន្ទាប់ពីមានការកើនឡើងនៃចំនួនសមាជិកសភាជាស្ត្រី។

- ច្បាប់ស្តីពីការស្នងមរតក (១៩៩៩) បង្កើតសមភាពយេនឌ័រនៅក្នុងការទទួលមរតក និងកម្មសិទ្ធិលើទ្រព្យសម្បត្តិ។
- រដ្ឋធម្មនុញ្ញ (២០០៣) ចែងពីគោលការណ៍នៃសមភាពយេនឌ័រ និងការមិនរើសអើង ដោយបញ្ជាក់ថា ស្ត្រីត្រូវតែមានយ៉ាងតិច៣០ភាគរយនៃមុខតំណែងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត។
- គោលនយោបាយដីធ្លីជាតិ (២០០៤) និងច្បាប់ស្តីពីដីធ្លី (២០០៥) ចែងពីសមភាពនៅក្នុងកម្មសិទ្ធិដីធ្លីស្របច្បាប់និងតាមប្រពៃណី។
- គោលនយោបាយដីធ្លីជាតិ (២០០៤) និងច្បាប់ស្តីពីដីធ្លី (២០០៥) ចែងពីសមភាពនៅក្នុងកម្មសិទ្ធិដីធ្លីស្របច្បាប់និងតាមប្រពៃណី។
- ច្បាប់ស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្មអំពើហឹង្សាពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានអនុម័ត (២០០៨) ហើយការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ត្រូវបានដាក់ជាទោសឧក្រិដ្ឋ (២០០៩)។
- ៥១ភាគរយនៃសមាជិកសភា និងពាក់កណ្តាលនៃចៅក្រមតុលាការកំពូល គឺជាស្ត្រីរួមទាំងប្រធានតុលាការផងដែរ (២០១១)។




ប្រភព៖ IPU 2010a និង 2011a

# ដាក់សមភាព យេនឌ័រនៅចំ កណ្ដាលគោលដៅ អភិវឌ្ឍន៍ សហស្សវត្ស

គោលដៅអភិវឌ្ឍន៍សហស្សវត្សពឹងផ្អែកគ្នាទៅវិញទៅមកហើយគោលដៅនីមួយៗពឹងផ្អែកលើការធ្វើឲ្យមានវឌ្ឍនភាពលើសិទ្ធិស្ត្រី។ ការពង្រីកការវិនិយោគ និងសកម្មភាពលើទិដ្ឋភាពសមភាពយេនឌ័រនៃគោលដៅទាំងអស់មានអត្ថប្រយោជន៍ទ្វេដងក្នុងការដោះស្រាយបញ្ហាវិសមភាពដែលកាន់តែរីករាលដាលនិងការពន្លឿនវឌ្ឍនភាពជារួមផងដែរ។

ការសម្រេចបានគោលដៅទាំងនេះ ក៏ជាការព្យាករណ៍ជាសារវ័ន្តមួយផងដែរសម្រាប់ស្ត្រីទទួលបានយុត្តិធម៌។ ប្រសិនបើគ្មានការអប់រំ ការយល់ដឹងអំពីសិទ្ធិ និងអំណាចនៃការធ្វើសេចក្ដីសម្រេចចិត្តទេ ស្ត្រីនឹងមិនអាចទាមទារសិទ្ធិរបស់ខ្លួនទទួលបានជំនួយផ្នែកច្បាប់ ឬទៅតុលាការនោះទេ។

ខណៈពេលដែលភាពជឿនលឿនត្រូវបានធ្វើឡើង រួមមានការកាត់បន្ថយភាពក្រីក្រ និងមរណភាពកុមារ និងការបង្កើនលទ្ធភាពទទួលបានការអប់រំ ទិន្នន័យបង្ហាញថាវឌ្ឍនភាពជារួម មិនបានរំលេចពីវិសមភាពដោយផ្អែកលើយេនឌ័រ ប្រាក់ចំណូល និង ទីកន្លែងនោះទេ។

ស្ត្រីនិងក្មេងស្រី ជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ជនបទគឺជាអ្នកដែលបានទទួលនូវវឌ្ឍនភាពតិចជាងគេបំផុតដោយក្នុងនោះស្ត្រីនិងក្មេងស្រីរាប់លាននាក់នៅតែរស់នៅក្នុងភាពក្រីក្រ និងការផាត់ចេញពីសង្គម។ ឧទាហរណ៍ ស្ត្រីក្រីក្រនៅក្នុងតំបន់ជនបទទំនងជាទទួលបានការថែទាំតិចតួចពីបុគ្គលិកជំនាញនៅពេលសម្រាលកូនដែលមានសារៈសំខាន់ជាសារវ័ន្តសម្រាប់បង្ការមរណភាពនិងភាពមានជំងឺបើប្រៀបធៀបជាមួយស្ត្រីជាអ្នកមាននៅក្នុងតំបន់ទីប្រជុំជន (មើលរូបភាពទី៧)។ ដោយនៅសល់តែបួនឆ្នាំទៀតប៉ុណ្ណោះរហូតដល់ឆ្នាំ២០១៥ កាលបរិច្ឆេទគោលដៅសម្រាប់សម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស ការបញ្ចប់អយុត្តិធម៌ពាក់ព័ន្ធនឹងយេនឌ័រដែលបង្កើតជារបាំងចំពោះឱកាសរបស់ស្ត្រីនិងក្មេងស្រីត្រូវតែជាចំណុចកណ្ដាលនៃសកម្មភាពបន្ថែមទៀត។ វិធីជាក់ស្ដែងខ្លះចំពោះការដាក់សិទ្ធិស្ត្រី នៅចំចំណុចកណ្ដាលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរួមមាន៖ ការលុបបំបាត់ថ្លៃសេវាសម្រាប់ការថែទាំសុខភាពដែលត្រូវបានបង្ហាញថាបានបង្កើនលទ្ធភាពរបស់ស្ត្រីនិងក្មេងស្រីក្នុងការទទួលបានសេវាក្នុងនោះរួមទាំងសុខភាពបន្តពូជការប្រើប្រាស់ប្រាក់លើកទឹកចិត្តនិងការផ្ទេរសាច់ប្រាក់ដើម្បីលើកទឹកចិត្តក្មេងស្រីឲ្យទៅសាលារៀនពន្យារពេលការរៀបការនិងបន្តការអប់រំរបស់ពួកគេសម្រាប់មធ្យមសិក្សាដែលជាឆ្នាំសំខាន់ការដាក់ស្ត្រីនៅលើជួរមុខនៃការផ្ដល់សេវាដើម្បីធ្វើឲ្យសេវាសាធារណៈកាន់តែអាចប្រើប្រាស់បាននិងការបង្កើនសម្លេងស្ត្រី នៅក្នុងការធ្វើការសម្រេចចិត្តពីថ្នាក់គ្រួសាររហូតដល់ថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ដើម្បីធានាថាគោលនយោបាយឆ្លុះបញ្ចាំងពីតថភាពនៃជីវិតពិតរបស់ស្ត្រី។

រូបភាពទី៧៖ ការថែទាំដោយបុគ្គលិកជំនាញនៅពេលសម្រាលកូន ស្ត្រីអ្នកមាននៅទីក្រុង និងស្ត្រីក្រីក្រនៅជនបទ

ស្ត្រីក្រីក្រនៅជនបទទំនងជាទទួលបានជំនួយពីបុគ្គលិកសុខាភិបាលជំនាញតិចជាងស្ត្រីជាអ្នកមានក្នុងពេលសម្រាលកូន។




ប្រភព៖ Seck និង Azcona 2010។ ផ្អែកលើការគណនាដែលបានរៀបចំឡើងដោយអង្គការ UN Women ពី Harttgen និង Klasen 2010.

UN Women គឺជាអង្គការរបស់សហប្រជាជាតិដែលមានគោលដៅលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី។ក្នុងនាមជាស្ថាប័ននាំមុខគេក្នុងសកលលោកមួយសម្រាប់ស្ត្រី និងក្មេងស្រី អង្គការ UN Women ត្រូវបានបង្កើតឡើងដើម្បីពន្លឿនវឌ្ឍនភាពក្នុងការសម្រេចបាននូវសិទ្ធិរបស់ស្ត្រីនិងក្មេងស្រីនៅទូទាំងពិភពលោក។

UN Women គាំទ្រដល់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិនៅខណៈពេលរដ្ឋជាសមាជិកបានកំណត់នូវនិយាមជាសកលលោកសម្រាប់សម្រេចបានសមភាពយេនឌ័រ និងធ្វើការជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីតាក់តែងច្បាប់គោលនយោបាយ កម្មវិធី និងសេវាកម្មនានាដែលត្រូវការដើម្បីអនុវត្តនិយាមទាំងនេះ។ អង្គការនេះឈរនៅពីក្រោយការចូលរួមដោយស្មើភាពរបស់ស្ត្រីនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ដោយផ្តោតទៅលើផ្នែកជាអាទិភាពចំនួន៥៖ បង្កើនភាពជាអ្នកដឹកនាំនិងការចូលរួមរបស់ស្ត្រីបញ្ចប់អំពើហឹង្សាប្រឆាំងនឹងស្ត្រី ឲ្យស្ត្រីចូលរួមនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការសន្តិភាពនិងសន្តិសុខលើកស្ទួយភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងការធ្វើឲ្យសមភាពយេនឌ័រជាចំណុចកណ្តាលនៃការ កសាងផែនការអភិវឌ្ឍន៍ជាតិនិងការរៀបចំថវិកា។ អង្គការ UN Women ក៏សម្របសម្រួល និងជំរុញផងដែរដល់ការងាររបស់សហប្រជាជាតិនៅក្នុងការសម្រេចននូវសមភាពយេនឌ័រ។

FSC
www.fsc.org
MIX
From responsible sources
FSC® CO12909

UN WOMEN

United Nations Entity for Gender Equality and the Empowerment of Women

220 East 42nd Street
New York, New York 10017, USA
Tel: 212-906-6400
Fax: 212-906-6705

http://progress.unwomen.org
www.facebook.com/unwomen
www.twitter.com/un_women
www.youtube.com/unwomen
www.flickr.com/unwomen